NGO-CEDAW
គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ

គណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW)

# សេចក្តីថ្លែងការណ៍រួម

NGO-CEDAW[1] និង CAMBOW[2] ជាសម្ព័ន្ធនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដែលធ្វើសកម្មភាពដើម្បីភាពរីកចម្រើននៃសិទ្ធិរបស់ស្ត្រី ព្រមទាំងធ្វើការឃ្លាំមើលនូវការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW)។

នាកាសថ្ងៃបុណ្យសិទ្ធិមនុស្សអន្តរជាតិ ១០ធ្នូនេះ យើងខ្ញុំសូមអំពាវនាវដោយទទូចដល់រាជរដ្ឋាភិបាលកម្ពុជា សូមលោកមេត្តាគោរព និងអនុវត្តតាមការប្តេជ្ញាចិត្តខ្លួនដូចមានចែងនៅក្នុងមាត្រា៣៨ និង៣៩ នៃរដ្ឋធម្មនុញ្ញ មាត្រា១៤ នៃកតិកាសញ្ញា អន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយដែលកម្ពុជាបានចុះហត្ថលេខាក្នុងឆ្នាំ១៩៩២ ។

យើងខ្ញុំក៏សង្ឃឹមផងដែរថាការគោរព និងអនុវត្តទៅតាមមាត្រា១០ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស បានផ្តល់នូវសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ និងជាសាធារណៈពីសំណាក់សាលាក្តីឯករាជ្យ និងមិនលំអៀងដល់ពលរដ្ឋខ្មែរ។

យើងខ្ញុំសូមធ្វើការថ្កោលទោសចំពោះការចាប់ខ្លួន ការឃុំខ្លួន និងការផ្តន្ទាទោសតំណាងសហគមន៍ទាំង១៨ នាក់ នៅបន្ទាប់ពីពួកគាត់បានធ្វើការតវ៉ានៅរាជធានីភ្នំពេញ។

តំណាងសហគមន៍បឹងកក់ទាំង ១៨ នាក់ដែលត្រូវបានចាប់ខ្លួន រួមមាន លោក ស៊ុំ ពុទ្ធី, លោក ឧកញ៉ា ពេជ្រសំណាង, អ្នកស្រី ង៉ែត ឃុន, អ្នកស្រី ទេព វន្នី, កញ្ញា សុង ស្រីលាភ, អ្នកស្រី គង់ ចន្ថា , អ្នកស្រី ផាន់ ឈុនរ៉េត, កញ្ញា ប៊ូ ឆវី , អ្នកស្រី នង ស្រេង, លោក មាជ សុវណ្ណារ៉ា , លោកស្រី ហេង ពេជ្រ , លោកស្រី អឹម ស្រីទូច , លោកស្រី ភួង សុភាព, ព្រះតេជគុណ ឃីត វណ្ណៈ, ព្រះតេជគុណ សាង កុសល, ព្រះតេជគុណ សឹង ហៃ , លោកទេព ណារិន និង លោកស្រី លី សៀវមីញ ។

យើងខ្ញុំសូមអំពាវនាវដោយទទូច សូមឲ្យដោះលែងអ្នកទាំង១៨ នាក់ និងអង្គ ដែលកំពុងឃុំខ្លួននៅមណ្ឌលកែប្រែ១ និងមណ្ឌលកែប្រែ២ ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ។ ជាពិសេសយើងខ្ញុំសូមទទូចដល់រដ្ឋាភិបាល សូមលោកមេត្តាគោរព និងអនុវត្តទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនានាដែលបានផ្តល់សច្ចាប័ន ។

ភ្នំពេញ ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ២០១៤

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង:

- កញ្ញា អ៊ូ ទេពផល្លីន លេខទូរស័ព្ទ:០១១៩៨៤៨៨៣ សមាជិកគណ:អចិន្ត្រៃយ៍នៃ NGO-CEDAW
- លោក ហេង សំអ៊ិន លេខទូរស័ព្ទ:០១៥៧៧០១២០ សមាជិកគណ:អចិន្ត្រៃយ៍នៃ NGO-CEDAW

---

[1] NGO-GEDAW មានសមាជិកចំនួន ៧២ អង្គការ ។

[2] CAMBOW មានសមាជិក ៣៥ អង្គការ ។